**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ : ១០២៦ សជណ.សរ**

*រាជធានីភ្នំពេញ*, ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមទូលថ្វាយ និងគោរពជូន**

**អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងប្រធានគ្រប់ស្ថាប័ន**

**កម្មវត្ថុ** : ស្តីពីការឆ្លើយបំភ្លឺជូនគណៈកម្មការនានានៃរដ្ឋសភា ។

**យោង** : មតិណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ។

តាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទូលបង្គំ ខ្ញុំមានកិត្តិយសូមទូលថ្វាយ និងគោរពជម្រាបជូនអ្នកអង្គម្ចាស់ ឯកឧត្តម និងលោកជំទាវ ព្រះមេត្តា និងមេត្តាជ្រាបថា : កន្លងមកថ្មីៗនេះ គណៈកម្មការនៃរដ្ឋសភា បានឆ្លើយដោយផ្ទាល់សុំការបំភ្លឺពីក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នមួយចំនួន ចំណុះរាជរដ្ឋាភិបាល ។ ដើម្បីធានាឱ្យមានភាពរលូនក្នុងកិច្ចដំណើរការការងារ និងការសហការរវាងស្ថាប័នរាជរដ្ឋាភិបាល និងរដ្ឋសភា សូមស្នើគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងអត្ថបទសម្រាប់ឆ្លើយបំភ្លឺជូនគណៈកម្មការនានានៃរដ្ឋសភា រួចផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីសម្តេចនាយករដ្ឋមន្ត្រី មុននិងឆ្លើយបំភ្លឺជាផ្លូវការទៅគណៈកម្មការនានានៃរដ្ឋសភា ។

អាស្រ័យហេតុដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមអ្នកអង្គម្ចាស់ ឯកឧត្តម និងលោកជំទាវ ព្រះមេត្តា និងមេត្តាជ្រាប ព្រមទាំងចាត់ចែងអនុវត្តតាមការគួរ ។

សូមអ្នកអង្គម្ចាស់ ឯកឧត្តម និងលោកជំទាវ ព្រះមេត្តា និងមេត្តាទទួលនូវការគោរពដ៏ស្មោះអំពីទូលបង្គំខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

ចម្លងជូន:

-អគ្គលេខាធិការរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ឯកសារ-កាលប្បវត្តិ